# ការចាត់ចែងចំពោះអ្នកដែលនឹងចូលមកប្រទេសជប៉ុន

ថ្ងៃទី26 ខែមិថុនា ឆ្នាំរេយវ៉ា 2 (ឆ្នាំ2020)
(បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី7 ខែតុលា ឆ្នាំ2022)
ទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន
Immigration Services Agency of Japan

## 1 អ្នកដែលគេបានផ្តល់ជូននូវលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ ឬអ្នកដែលកំពុងដាក់ពាក្យសុំលិខិតបញ្ជាក់លក្ខណៈសម្បត្តិស្នាក់នៅ

(1) **អ្នកដែលគេបានផ្តល់ជូននូវលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ**

តាមធម្មតា សុពលភាពគឺ 3ខែ ក៏ប៉ុន្តែមានការចាត់ទុកពិសេសដូចតទៅ៖

○លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅណាដែលធ្វើឡើងក្នុងកម្លុងពេលពីថ្ងៃទី1 មករា 2020 ដល់ថ្ងៃទី30 មេសា 2022 ត្រូវបានចាត់ទុកថា មានសុពលភាពដល់ថ្ងៃទី 31 តុលា 2022 ។

○លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅណាដែលធ្វើឡើងក្នុងកម្លុងពេលពីថ្ងៃទី1 ឧសភា 2022 ដល់ថ្ងៃទី 31 កក្កដា 2022 ត្រូវបានចាត់ទុកថា មានសុពលភាព 6 ខែ ដោយគិតពីថ្ងៃដែលបានធ្វើនោះ។

* ក្នុងករណីដាក់ពាក្យស្នើសុំ លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅមុនថ្ងៃទី31 ខែមករា ឆ្នាំ2023 ដែលគ្មានខ្លឹមសារប្រែប្រួលចាប់តាំងពីពេលដាក់ពាក្យលើកមុននោះ ជាគោលការណ៍ នៅពេលដាក់①លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅដែលត្រូវបានចេញលើកមុន(ឯកសារដើម ឬថតចម្លង) និង ②លិខិតបញ្ជាក់មូលហេតុដែលធ្វើឡើងដោយស្ថាប័នទទួល ។ល។ នោះលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅថ្មីនឹងត្រូវបានផ្តល់ឱ្យជាបន្ទាន់។ ព័ត៌មានលំអិត សូមមើល<u>កន្លែងនេះ</u>។

(2) **ចំពោះអ្នកដែលកំពុងដាក់ពាក្យសុំលិខិតបញ្ជាក់ការទទួលស្គាល់នូវលក្ខណៈសម្បត្តិស្នាក់នៅ**

ស្តីពីករណីដែលកំពុងដាក់ពាក្យសុំនេះ ហើយបើសិនជាមានការប្តូរពេលចាប់ផ្តើមធ្វើសកម្មភាព ជាគោលការណ៍ គេធ្វើការពិនិត្យសំណូមពាក្យដោយមើលតែលិខិតបញ្ជាក់មូលហេតុដែលធ្វើឡើងដោយស្ថាប័នទទួលប៉ុណ្ណោះ។

## 2 អ្នកដែលបានចេញពីជប៉ុន ដោយមានការអនុញ្ញាតឱ្យចូលវិញ នៅពេលកំពុងដាក់ពាក្យសុំពាក់ព័ន្ធនឹងការស្នាក់នៅ

**[សម្គាល់] ការចាត់ចែងនេះមិនអនុវត្តន៍ចំពោះការស្នើសុំដែលបានដាក់ជូនត្រឹមឬក្រោយ<u>ថ្ងៃទី11 ខែតុលា ឆ្នាំ2022</u> ទេ។**

ក្នុងករណីដែលអ្នកដែលកំពុងចេញទៅប្រទេសក្រៅ ដោយមានការអនុញ្ញាតឱ្យចូលវិញ (រួមទាំងការចាត់ទុកថា មានការអនុញ្ញាតឱ្យចូលវិញ) បានដាក់ពាក្យសុំនូវការអនុញ្ញាតប្តូរលក្ខណៈសម្បត្តិស្នាក់នៅ ឬសុំការអនុញ្ញាតពន្យារលក្ខណៈសម្បត្តិស្នាក់នៅ ឬសុំការអនុញ្ញាតការស្នាក់នៅអចិន្ត្រៃយ៍ មុនពេលចេញពីជប៉ុន ហើយមិនអាចត្រឡប់មកវិញបានដោយសារឥទ្ធិពលនៃជម្ងឺឆ្លងកូវីដ១៩, គេទទួលស្គាល់នូវការទទួលជំនួសនូវប័ណ្ណស្នាក់នៅ ពាក់ព័ន្ធនឹងការអនុញ្ញាតនៃការដាក់ពាក្យសុំនេះ ដោយសាច់ញាតិនៅជប៉ុន ឬដោយបុគ្គលិកនៃស្ថាប័នទទួល ជាអាទិ៍ ហើយអ្នកដែលកំពុងចេញពីជប៉ុន អាចដាក់ពាក្យសុំចូលតាមរយៈការអនុញ្ញាតឱ្យចូលវិញ។

## 3 អ្នកដែលកម្លុងពេលអាចចូលវិញបានកន្លងផុតទៅហើយ នៅពេលកំពុងចេញពីជប៉ុនដោយមានការអនុញ្ញាតឱ្យចូលវិញ ជាអាទិ៍

**[សម្គាល់] ការចាត់ចែងនេះមានសុពលភាពរហូតដល់<u>ថ្ងៃទី30 ខែមេសា ឆ្នាំ2023</u>។ *សូមយោងលើតំណភ្ជាប់នីមួយៗសម្រាប់សេចក្តីលម្អិត។**

(1) អ្នកដែលមិនមែនជាមុខសញ្ញានៃការផ្តល់លិខិតទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ ("អ្នកស្នាក់នៅអចិន្ត្រៃយ៍" ជាអាទិ៍)

សូមទៅដាក់ពាក្យសុំទិដ្ឋាការនៅស្ថានទូតឬកុងស៊ុលជប៉ុននៅប្រទេសដែលស្នាក់នៅ។

※ស្តីពីអ្នកស្នាក់នៅអចិន្ត្រៃយ៍ ព័ត៌មានលំអិត សូមមើល<u>កន្លែងនេះ</u>។

※ស្តីពី "អ្នកស្នាក់នៅជាប់លាប់(ក្រៅពីការប្រកាសជាសាធារណៈ)" និង "សកម្មភាពពិសេស (ក្រៅពីការប្រកាសជាសាធារណៈ)" ព័ត៌មានលំអិត សូមមើល<u>កន្លែងនេះ</u>។

(2) អ្នកដែលជាមុខសញ្ញានៃការចេញលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ (និស្សិត, កម្មសិក្សាការីហ្វឹកហ្វឺនជំនាញ, វិទ្យាសាស្ត្រ-ចំណេះដឹងអំពីមនុស្សសាស្ត្រ-ការងារអន្តរជាតិ ជាអាទិ៍)

អ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅជប៉ុនរយៈពេលវែង (និស្សិត ឬកម្មសិក្សាការីហ្វឹកហ្វឺនជំនាញ ជាអាទិ៍) ហើយមិនអាចត្រឡប់មកវិញដោយសារឥទ្ធិពលនៃជម្ងឺឆ្លងកូវីដ១៩ ជាគោលការណ៍ គេធ្វើការពិនិត្យតែសំណូមពាក្យ និង លិខិតបញ្ជាក់មូលហេតុដែលធ្វើឡើងដោយស្ថាប័នទទួលប៉ុណ្ណោះ។ ※ព័ត៌មានលំអិត សូមមើល<u>កន្លែងនេះ</u>។

(3) អ្នកដែលស្នាក់នៅដោយលក្ខណៈសម្បត្តិ "ឯកទេសកម្រិតខ្ពស់ លេខ 2"

សូមដាក់ពាក្យសុំលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅទៅតាមសកម្មភាពដែលបានធ្វើពីមុន ក្នុងនាមជា "ឯកទេសកម្រិតខ្ពស់<u>**លេខ 1**</u>" យោងតាមចំណុច (2) ។ (គេនឹងចេញទិដ្ឋាការដោយមានលក្ខណៈសម្បត្តិស្នាក់នៅ "ឯកទេសកម្រិតខ្ពស់លេខ 1" តែពេលមកដល់ជប៉ុន អាចធ្វើនីតិវិធីចូលប្រទេសជប៉ុនជាថ្មីដោយមានលក្ខណៈសម្បត្តិ "ឯកទេសកម្រិតខ្ពស់លេខ 2" នៅអាកាសយានដ្ឋានជប៉ុនពេលចូលវិញបាន។)